**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ៖ ២៧៦៥ សកបយ.

ភ្នំពេញ. ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ម្រេ ច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវប្រើ និងរក្សាទុកអោយបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមួយ ដែលអធិការការងារបានចុះលេខរៀង និងចុះហត្ថលេខាសង្ខេប ។ គំរូសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** និយោជក ឬអ្នកតំណាងត្រូវជូនសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននេះ ទៅអធិការការងារ ឬអធិការការងារ ត្រួតពិនិត្យនិងធ្វើការសង្កេត ធ្វើការផ្តល់ដំបូន្មាន ឬធ្វើការដាក់កំហិតផ្សេងៗ នៅរាល់ពេលចុះត្រួតពិនិត្យ ។

<u>ប្រការ៣</u>.- សៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដែលបានប្រើប្រាស់គ្រប់ទំព័រទាំងអស់ហើយ និយោជកត្រូវថែរក្សាទុកអោយគង់ក្នុងរយៈពេល ៣ ឆ្នាំ។ អធិការការងារ និងអភិបាលការងារអាចទាររកសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននោះ នៅគ្រប់ពេលវេលា។

<u>ប្រការ៤</u>.- អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងនៅក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ។

<u>ប្រការ៥</u>.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩២ សកអ.ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍។

<u>ប្រការ៦</u>.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

អ៊ិត សំហេង

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ

នៃ

ប្រកាសលេខ :......................

ចុះថ្ងៃទី........ខែ.........ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

..................ថ្ងៃទី........ខែ...........ឆ្នាំ...........

ទំហំ ២០សម X ៣០សម

-ឈ្មោះគ្រឹះស្ថាន :........................................................................
........................................................................

-ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច :........................................................................
........................................................................

-អាសយដ្ឋាន :........................................................................
........................................................................

-នាមនិងគោត្តនាមនិយោជក :........................................................................
........................................................................

-កាលបរិច្ឆេទនៃការចេញសៀវភៅបញ្ជី :........................................................................
........................................................................

ផ្ទះព្រាហ្មណលេខា លេខទំព័រ:...............

របស់អធិការការងារ